# សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៨

## បទបង្ហាញស្តីពី បញ្ហាប្រឈមក្នុងដំណើរវិវត្តនវិស័យឯកជន និងអភិបាលកិច្ច

## អេង នេត្រា

១. បទបង្ហាញនេះ ផ្តល់ជូនដោយត្រួសៗនូវចំនុចគន្លឹះមួយចំនួននៅក្នុងប្រព័ន្ធអភិបាលកិច្ចរបស់កម្ពុជា ព្រមទាំងលើកមកពិភាក្សានូវឥទ្ធិពលរបស់វាទៅលើដំណើរវិវត្តនវិស័យឯកជន ព្រមទាំងផ្តល់ជូននូវសេណារីយ៉ូខ្លះៗ សំដៅដោះស្រាយបញ្ហាប្រឈមទាំងនោះ ។

២. កម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ ក្នុងរយៈពេល ១៥ឆ្នាំកន្លងទៅនេះ ។ សន្តិភាពដែលកើតមានឡើងបន្ទាប់ពីសង្គ្រាមបានចប់ បានបង្កអោយមានស្ថិរភាពដែលជាកត្តាសំខាន់នាំមកនូវការរីកចំរើនសេដ្ឋកិច្ចលើគ្រប់វិស័យ ។ ការរីកចំរើនទាំងនេះជួយអោយ រដ្ឋាភិបាលសំរេចបាននូវកំណើនសេដ្ឋកិច្ចខាងលើ ។

៣. ជោគជ័យទាំងនេះបានកើតឡើង ទោះជាមានបញ្ហាប្រឈមខាងផ្នែក ការគោរពសិទ្ធិមនុស្ស និតិរដ្ឋ និងគុណភាពមានកំរិតនៃអភិបាលកិច្ចជាទូទៅក៏ដោយ ។

៤. ទាក់ទិននឹងគុណភាពនៃអភិបាលកិច្ចនៅកម្ពុជា ការទិតៀនវាងាយស្រួលទេ ក៏ប៉ុន្តែតាមពិតវាមានភាពសាំញ៉ាំ និងពិបាកក្នុងការធ្វើកំណែទម្រង់មែន ។ បញ្ហាលំបាកធំៗរួមមានៈ

៥. ការសិក្សារបស់វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា លើភាពក្រីក្រ បានបង្ហាញថា អ្នកក្រីក្រនៅមិនទាន់បានទទួលផលពីការអនុវត្តគោលនយោបាយអភិវឌ្ឍន៍នៅឡើយទេ ហើយជារឿយៗក៏នៅមិនទាន់ទទួលបាននូវសេវាមូលដ្ឋានសាធារណៈនៅឡើយដែរ ។ ទន្ទឹមនឹងនេះ អ្នកក្រីក្រក៏ទទួលបានចំណាត់ការមិនស្មើភាព និងទទួលរងផលប៉ះពាល់អវិជ្ជមានពីសកម្មភាពពុករលួយរបស់មន្ត្រីរដ្ឋាភិបាលផងដែរ ។ ការសិក្សាក៏បានរកឃើញដែរថា ការចាប់យកប្រយោជន៍របស់ក្រុមវណ្ណៈខ្ពស់អេលីត និងប្រព័ន្ធខ្សែខ្នង អាចធ្វើអោយពួកគេអាចប្រើអំណាចទាញយកផលចំណេញតាមដែលពួកគេចង់បាន ហើយប្រព័ន្ធនេះក៏បានដាក់កំហិតដល់ប្រជាជនក្នុងការប្រើប្រាស់ធនធានធម្មជាតិ និងការចូលរួមក្នុងការសំរេចចិត្តផងដែរ ។

៦. ការសិក្សាដ៏ទៃទៀតរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាយជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ស្តីពីគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ បានរកឃើញថា ប្រព័ន្ធអភិបាលកិច្ចនៅកម្ពុជាបានទទួលជោគជ័យតិចតួចនៅឡើយ ក្នុងការចាត់ចែងថវិកាសាធារណៈអោយមានប្រសិទ្ធភាព តាមរយៈការចំណាយដោយមានមូលហេតុសមស្រប និងការតភ្ជាប់ទៅនឹងផែនការយ៉ាងត្រឹមត្រូវ ។ លើសពីនេះ ក៏មានការខកខានក្នុងការជ្រើសរើស និងផ្តល់រង្វាន់ដល់មន្ត្រីរាជការដែលមានសមត្ថភាពទៅតាមគោលការណ៍គុណូបធិតេយ្យ ។ ការសិក្សាក៏បានលើកពី ចំណុចខ្សោយនៃប្រព័ន្ធ បច្ចេកទេស/ផ្លូវការ និងកម្លាំងខ្លាំងជាងនៃ បណ្តាញ មិនផ្លូវការ/ខ្សែខ្នង នៅគ្រប់លំដាប់ថ្នាក់ ក្នុងប្រព័ន្ធអភិបាលកិច្ចនៅកម្ពុជា ។

លើសពីនេះទៀត បណ្ដាញមិនផ្លូវការ/ខ្សែខ្នងនេះ ត្រូវបានពង្រឹងខ្លាំងឡើងៗក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ។

៧. ការប្រមូលចំណូលនៅជួបបញ្ហាជាច្រើន ក្នុងនោះ បរិមាណចំណូលពន្ធអាករស្របច្បាប់ ដែលប្រមូលតាមរយៈក្របខ័ណ្ឌផ្លូវការ នៅមានបរិមាណតិចតួចក្នុងការជួយទ្រទ្រង់ថវិកាជាតិទាំងមូល ។ ផ្ទុយទៅវិញ នាបច្ចុប្បន្ននេះមានចំណូលមួយចំណែកធំមិនបានហូរតាមប្រព័ន្ធផ្លូវការទេ ប៉ុន្តែកំពុងហូរតាមប្រព័ន្ធមិនផ្លូវការ/ខ្សែខ្នង ហើយថវិកាមិនផ្លូវការនេះវាជួយពង្រឹង និងរក្សាបណ្ដាញខ្សែខ្នងរវាង អ្នកក្រោមបង្គាប់ និងថ្នាក់លើ ដែលស្ថិតក្នុងក្រុមតែមួយ ។

៨. ការសង្កេតឃើញពិសេសមួយលើការអភិវឌ្ឍប្រទេសកម្ពុជាក្រោយសម័យសង្គ្រាម គឺ ការលើកដំកើងសកម្មភាពសប្បុរសជនក្នុងការទ្រទ្រង់គំរោងអភិវឌ្ឍន៍ និងគំរោងខាងផ្នែកសាធារណៈការនានា ។ ការអភិវឌ្ឍក្នុងរូបភាពនេះ បានជួយរួមចំណែកយ៉ាងច្រើនដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធមួយចំនួន ដូចជា ផ្លូវថ្នល់ វត្តអារាមសាលារៀន និងប្រព័ន្ធធារាសាស្ត្រ ។ នៅក្នុងការអភិវឌ្ឍតាមរយៈសប្បុរសជននេះ អ្នកក្រចាំតែទទួលយកនូវរាល់ជំនួយដោយគ្មានការតវ៉ា ហើយពួកគាត់ត្រូវបង្ហាញពីការដឹងគុណចំពោះសប្បុរសជនទាំងនោះផង ។ ប្រព័ន្ធបែបនេះទប់ស្កាត់មិនអោយមានយន្តការគណនេយ្យភាព ដែលជួយធានាអោយមានតម្លាភាពក្នុងការចាយវាយថវិកា ។

៩. ជារួម តើដំណើរនេះជះឥទ្ធិពលអ្វីខ្លះទៅលើការវិវត្តវិស័យឯកជន? ទិន្នន័យក្នុងរបាយការណ៍ "ការធ្វើអាជីវកម្មឆ្នាំ២០០៨ " ចេញដោយធនាគារពិភពលោក បានផ្ដល់ឱ្យប្រទេសកម្ពុជានូវចំណាត់ថ្នាក់លេខ ១៤៥ ក្នុងចំណោម ១៧៨ ប្រទេស សំរាប់ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម ។ របាយការណ៍នេះ ក៏បានធ្វើការប្រៀបធៀបលើចំនុចមួយចំនួន ជាមួយនឹងឆ្នាំមុនដែរ ។ ចំណុចវិជ្ជមានគឺ នៅឆ្នាំ២០០៨ ប្រទេសកម្ពុជាអាចកែលំអបានបន្តិចលើការបើកធ្វើអាជីវកម្មថ្មី ការស្នើសុំអាជ្ញាប័ណ្ណ និងចំណុចគួរអោយភ្ញាក់ផ្អើលគឺ លើការជួលបុគ្គលិក ។ ក៏ប៉ុន្តែសំរាប់វិនិយោគិនបរទេសវិញ កម្ពុជានៅមានចំនុចអវិជ្ជមានមួយចំនួនដូចជា ភាពមិនប្រាកដប្រជាផ្នែកគោលនយោបាយ អំពើពុករលួយ សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ប្រព័ន្ធតុលាការទន់ខ្សោយ និងឧក្រិដ្ឋកម្ម ។

១០. បញ្ហាចំបងៗសំរាប់វិនិយោគិន គឺមានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និងការអនុវត្តកិច្ចសន្យា ។ បញ្ហាភាគច្រើនកើតឡើងដោយសារប្រព័ន្ធតុលាការស្ថិតក្រោមចំណុះប្រព័ន្ធខ្សែខ្នង ដែលធ្វើអោយភាគីម្ខាងដែលគ្មានអំណាចត្រូវចំណាយច្រើន ព្រមទាំងអាចទទួលរងនូវផលមិនអាចស្មានទុកជាមុន នៅរាល់ពេលមានជម្លោះជាមួយបុគ្គលមានអំណាចដែលមានខ្សែខ្នងការពារពីក្រោយ ។

១១. កម្ពុជាអាចផ្ដល់ជូននូវមូលដ្ឋានដ៏រឹងមាំ ដល់ប្រភេទអាជីវកម្មមួយចំនួន អោយតែអាជីវកម្មទាំងនោះមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល ។ សំរាប់និយោគផ្ទាល់ពីបរទេសវិញ ការហូរចូលវិនិយោគមកពីប្រទេសចិនយ៉ាងសន្ធឹកសន្ធាប់នាពេលថ្មីៗ តាមរយៈក្រុមហ៊ុនផ្សេងៗដែលមានទំនាក់ទំនងរឹងមាំជាមួយក្រុមហ៊ុនកម្ពុជា ឬរដ្ឋាភិបាលកម្ពុជា បានបង្ហាញថា បរិយាកាសធ្វើវិនិយោគទុននៅកម្ពុជា មិនមានលក្ខណៈអវិជ្ជមានទាំងស្រុងទេ ។

១២. ការជំនះនូវបញ្ហាទាំងនេះ និងការព្យាយាមសំរេចអោយបាននូវគោលដៅកាត់បន្ថយភាពក្រី នៅតែជាបញ្ហាប្រឈមនៅឡើយ ។ ទោះជាយ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមធ្វើកំណែទម្រង់នាពេលថ្មីៗ (ដូចជាខាងផ្នែកវិមជ្ឈការ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) បានផ្តល់នូវក្តីសង្ឃឹមមួយចំនួនដែលគួរពិនិត្យតាមដាន និងបន្តធ្វើទៀត ។ សេណារីយ៉ូគោលនយោបាយវិជ្ជមានមួយចំនួន រួមមាន :

១៣. *រដ្ឋាភិបាលបន្តផ្តោតលើការការពារស្ថិរភាពនយោបាយ* ។ ដំណើរការបែបនេះ នឹងធ្វើអោយរាល់កំណែទម្រង់ និងការព្យាយាមធ្វើនាំអោយមានការផ្លាស់ប្តូរនានា ត្រូវយឺតយ៉ាវ និងមិនអាចកើតឡើងបានតាមការគ្រោងទុក ។

១៤. *ជំរុញកំណែទម្រង់វិមជ្ឈការ* ដែលនឹងឈានទៅដល់ការបង្កើតក្រុមប្រឹក្សាថ្នាក់ខេត្ត និងស្រុក តាមរយៈការបោះឆ្នោតឡើងដោយប្រយោល ។ ក្រុមប្រឹក្សានេះនឹងមានអំណាច និងធនធានគ្រប់គ្រាន់ ព្រមទាំងមានតួនាទីជាច្រើនដូចជា ការគ្រប់គ្រងធនធានធម្មជាតិ កសិកម្ម ការផ្តល់សេវាកម្ម ការប្រើប្រាស់ដីធ្លី និង អភិវឌ្ឍន៏សេដ្ឋកិច្ច ។ ជាបណ្តើរៗ ក្រុមប្រឹក្សាទាំងនេះនឹងក្លាយជា ចលករស្នូលក្នុងការធ្វើអោយមានការផ្លាស់ប្តូរ ហើយអាចទាមទារអោយរដ្ឋាភិបាលឆ្លើយតបទៅនឹងតម្រូវការថ្នាក់មូលដ្ឋាន អោយបានកាន់តែលឿន ។

១៥. *បន្តធ្វើអោយបានជោគជ័យនូវដំណើរការអនុវត្តកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ* ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើឡើង ហើយកំណែទម្រង់នេះសំដៅធ្វើអោយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកាន់តែមានតម្លាភាព និងប្រសិទ្ធភាព ។ ការប្រមូលចំណូល និងការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋ ហើយផ្នែកនេះត្រូវតែពង្រឹងជាចាំបាច់ ដើម្បីធ្វើអោយអភិបាលកិច្ចតាមប្រព័ន្ធខ្សែខ្នងចុះអន់ខ្សោយ និងធ្វើអោយរដ្ឋាភិបាលកាន់តែមានលទ្ធភាពឆ្លើយតបបានលឿនក្នុងការផ្តល់សេវាកម្មជូនប្រជាជន ។

១៦. *ធ្វើអោយប្រសើរឡើងនូវវេទិកាទំនាក់ទំនងរវាងរដ្ឋាភិបាល និងវិស័យឯកជន និងក្រុមការងារតាមផ្នែកទាំង៨* ដើម្បីអោយវេទិកានេះកាន់តែមានប្រសិទ្ធភាពក្នុងការធ្វើអោយមានការប្រាស្រ័យទាក់ទងគ្នា តាមរបៀបបើកចំហ និងត្រង់ទៅត្រង់មករវាងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងក្រុមដែលកំពុងធ្វើអាជីវកម្មជាក់ស្តែងនៅកម្ពុជា ។ ក្នុងខណៈពេលនេះ គេត្រូវមានការតាំងចិត្តយ៉ាងពិតប្រាកដ និងវេទិកាដ៏មានប្រយោជន៏នានា ដើម្បីធានាអោយមានគណនេយ្យភាព និងការឆ្លើយតបកាន់តែប្រសើរឡើង ពីសំណាក់រដ្ឋាភិបាលក្នុងការជួយដោះស្រាយបញ្ហាប្រឈមផ្សេងៗរបស់វិស័យឯកជន ។

១៧. *កំណើនចំនួន និងការឡើងឋានៈនៃមេដឹកនាំពាណិជ្ជករ និងក្រុមអេលីតថ្មីៗ* ដែលតំណាងឱ្យផលប្រយោជន៏មួយចំនួនក្នុងវិស័យពាណិជ្ជកម្មកម្ពុជា ។ ជាបណ្តើរៗ ក្រុមដែលមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយរដ្ឋាភិបាលនេះនឹងទាមទារអោយមានកំណែទម្រង់មួយចំនួនពីសំណាក់រដ្ឋាភិបាល ។